មជ្ឈមណ្ឌលឯកសារកម្ពុជា

# ជ័យ សុភារ៉ា ប្រាប់ពីប្រវត្តិរណ្តៅសាកសពនៅជាប់របងទួលស្លែង

---

ដោយៈ ផេង ពង្សរ៉ាស៊ី

លោក **ជ័យ សុភារ៉ា** អាយុ៥១ឆ្នាំ បច្ចុប្បន្នជាប្រធានសារៈមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ទួលស្លែងបាននិយាយថា ការគាស់រណ្តៅសាកសពនាពេលថ្មីៗនេះនៅជាប់របងទួលស្លែងប៉ែកខាងលិច ឆៀងខាងត្បូង ពិតជាមានការជាប់ទាក់ទងទៅនឹងអ្វីដែលបានកើតឡើងនៅក្នុងសារៈមន្ទីរជាតិទួលស្លែង ។

**សុភារ៉ា** ជាអ្នកនាំភ្ញៀវនៅសារៈមន្ទីរទួលស្លែងក្នុងចន្លោះឆ្នាំ១៩៧៩-៨០ ពេលដែលរដ្ឋ (សាធារណរដ្ឋប្រជាមានិតកម្ពុជា) បានបង្កើតតុលាការប្រជាជនមួយដើម្បីកាត់ទោសរបបខ្មែរក្រហម ហើយពេលនោះក៏មានគណៈប្រតិភូជាច្រើនចូលរួម ជាពិសេសមកពីប្រទេសសង្គមនិយម ។

បន្ទាប់មកក្រុមរបស់លោក **ជ័យ សុភារ៉ា** បានជីករណ្តៅមួយនៅខាងក្រោយរបងទួលស្លែង (ខាងលិចឈៀងខាងត្បូង) ដើម្បីឲ្យភ្ញៀវព្រមទាំងគណៈប្រតិភូមើល និងដឹងថា ពួកខ្មែរក្រហមពិតជាបានសម្លាប់ប្រជាជនយើងគ្រប់ទីកន្លែងទាំងអស់នៅក្នុងបរិវេណមន្ទីរស-២១(គុកទួលស្លែង) ក្នុងពេលដែលពួកគេកាន់កាប់អំណាច ១៩៧៥-៧៩ ។

លោក **ជ័យ សុភារ៉ា** បានដឹងថាមានរណ្តៅកប់ខ្មោចនៅខាងក្រោយរបងសារៈមន្ទីរទួលស្លែង ព្រោះគាត់ត្រូវបានប្រាប់ដោយទាហានម្នាក់ដែលអះអាងថាខ្លួនបានរត់រួចផុតពីមន្ទីរស-២១ នៅក្រោយថ្ងៃរំដោះ ១៩៧៩ ។ រហូតមកដល់បច្ចុប្បន្នលោក ជ័យ សុភារ៉ា នៅតែរកនឹកឈ្មោះទាហានម្នាក់នោះមិនឃើញដដែល ។

ក្រុមរបស់លោក **ជ័យ សុភារ៉ា** បានជ្រើសរើសយកមុខផ្ទះលោក **អាយស៊ុំ សុផល** ជាជាង កាត់ដេរស្បែកជើង ដើម្បីជីកបង្ហាញឲ្យគណៈប្រតិភូអន្តរជាតិដែលបានចូលរួមក្នុងការកាត់ទោសខ្មែរ ក្រហមឆ្នាំ១៩៧៩-៨០បានឃើញ ។ ពេលនោះ មិនទាន់មានផ្ទះប្រជាជនសង់នៅខាងក្រោយរបងសារៈមន្ទីរទួលស្លែងដូចសព្វថ្ងៃនេះទេ ។ មានតែសំណង់បាក់បែក កំពុកកំបាក់ស្ថិតនៅជាប់នឹងរណ្តៅព្រមទាំងមានដើមចេកមួយចំនួនស្ថិតនៅខាងក្រោយសារៈមន្ទីរប្រល័យពូជសាសន៍ទួលស្លែង(ស-២១) ។

ពេលជីកក៏ឃើញរណ្ដៅនោះមានខ្សែចំណងដៃ មានឆ្អឹង មានលលាដ៍ក្បាល...។ ក្រសួងសុខាភិបាលពេលនោះក៏បានចុះទៅពិនិត្យជាមួយក្រុមរបស់លោក**ជ័យ សុភារ៉ា** ព្រមទាំងមានការចូលរួមពីគ្រប់សមត្ថកិច្ចទាំងអស់ដែរ ។ ពេលជីកបានបន្តិចក៏ផ្អាកទៅវិញ ដោយមានជះក្លិនស្អុយខ្លាំងពេកពីរាងកាយសាកសពចេញពីរណ្ដៅដែលបានជីកនោះ ។

**សុភារ៉ា** បាននិយាយថាគាត់បាននាំយកឆ្អឹងពីកន្លែងផ្សេងៗដូចជាយកមកពីខេត្តស្វាយរៀងខ្លះ ទួលគោកខ្លះទៅដាក់នៅក្នុងរណ្ដៅនោះមួយចំនួន និងមួយចំនួនទៀតយកទៅលាង ស្ងោរដាក់ក្នុងខ្ទះ ដើម្បីយកមកធ្វើជាផែនទីប្រទេសកម្ពុជាដែលត្រូវបានតំរៀបភាគច្រើនជាលលាដ៍ក្បាលខ្មោច និងកំពុងត្រូវបានដាក់បង្ហាញក្នុងបន្ទប់មួយនៃអគារទួលស្លែងសព្វថ្ងៃនេះ ។ ពេលលាងឆ្អឹងទាំងនោះគាត់(សុភារ៉ា) សង្កេតឃើញ ពិសេសឆ្អឹងលលាដ៍ក្បាលមានជាប់ស្បែកនិងសក់ខ្លះៗផង ។

**សុភារ៉ា** បាននិយាយបន្តថា ប្រជាជនខ្មែរយើងនៅតែមានការសង្ស័យទៅ លើឆ្អឹងលលាដ៍ក្បាលដ៏ធំ និង ឆ្អឹងស្មងជើងដ៏វែងថាជាឆ្អឹងរបស់ជនជាតិបរទេស ។ យោងតាមសំដីរបស់គាត់ថា ខ្មែរយើងខ្លះក៏មានកំពស់ដូចបរទេសដែរ ដូច្នេះរឿងនេះយើងមិនអាចធ្វើការសន្និដ្ឋានបានឡើយ ។ បន្ទាប់មក **សុភារ៉ា** បានប្រាប់ថាក្នុងមួយរណ្ដៅនេះមានសាកសពជាង១០នាក់ ។ រណ្ដៅនោះត្រូវបានគ្របដោយកញ្ចក់មួយផ្ទាំងធំ រួចក៏បានធ្វើជារបងដាក់ខ្សែព័ទ្ធជុំវិញដើម្បីទុកឲ្យ គណៈប្រតិភូ និងអ្នកកាសែតមកទស្សនា ។ គាត់បានអះអាងថា ការគ្របកញ្ចក់មួយផ្ទាំងនេះ ក៏ជាវិធី មួយល្អសំរាប់ការពារកុំឲ្យសត្វផ្សេងៗស៊ី និង កុំឲ្យដីធ្លាក់ចូល ។

រណ្ដៅនេះត្រូវបានកប់ដីវិញ បន្ទាប់ពីស្ថានភាពនយោបាយមានការផ្លាស់ប្ដូរនៅឆ្នាំ១៩៩៣ ហើយរបងក៏ត្រូវវាយបំបែកអស់ដែរ ។ កញ្ចក់ដែលពាសពីលើរណ្ដៅនោះ មិនត្រូវបានគាស់ចេញឡើយនៅពេលដែលកប់ដីពីលើ ។ ទើបពេលថ្មីៗនេះម្ចាស់ផ្ទះឈ្មោះ **អាយស៊ី សុផល** ចង់សង់ផ្ទះក៏បានគាស់រណ្ដៅនោះ រួចក៏យកឆ្អឹងទាំងនោះទៅតម្កល់នៅវត្តទៅ ។ **សុភារ៉ា** បានបញ្ជាក់ថា អ្នកដែលបានសាងសង់ផ្ទះជុំវិញរបងទួលស្លែងប្រាកដជាមានប៉ះចំលើរណ្ដៅហើយ ។ គាត់ក៏បានបន្ថែមថា អ្នកខ្លះដឹងថាបានប៉ះចំរណ្ដៅហើយ ប៉ុន្តែចេះតែសម្ងំស្ងៀម ដឹងតែពីបន្តការសាងសង់ និងរស់នៅតទៅទៀត ។

កញ្ចក់ដែលបានបែកនាពេលថ្មីៗនេះមិនមែនជាស៊ុមកញ្ចក់ទេ គឺកញ្ចក់មួយផ្ទាំងធំគ្របពីលើ ។ កញ្ចក់ចាស់មួយផ្ទាំងនេះ **សុភាវ៉** ប្រាប់ថាបានគ្របនៅក្រោយ ឆ្នាំ១៩៧៩ ។

លោក **ជ័យ សុភាវ៉ា** បានបញ្ជាក់ថាការរកឃើញរណ្តៅសាកសពនាពេលថ្មីនេះនៅជាប់របងសារមន្ទីរទួលស្លែង ជារឿងកន្លងយូរមកហើយមិនមែនជារឿងថ្មីនោះទេ ។ ម្ចាស់ផ្ទះឈ្មោះ **អាយស៊ី សុផល** ក៏បានដឹងរឿងឆ្អឹងកប់ត្រង់នេះដែរ ប៉ុន្តែគាត់មិនបានធ្វើអ្វីទាំងអស់ទៅលើរណ្តៅនោះ ទើបតែពេលនេះគាត់បានសំរេចចិត្តធ្វើផ្ទះពីលើរណ្តៅនេះ ហើយក៏បានគាស់យកឆ្អឹងទាំងនោះចេញ ដើម្បីយកទៅធ្វើបុណ្យ ព្រមទាំងបានបួងសួងនិងខ្ទិសសុំសេចក្តីសុខសប្បាយក្នុងការសាងសង់ផ្ទះរបស់គាត់ ព្រោះនេះជាប្រពៃណីខ្មែរយើង ។

**ជ័យ សុភាវ៉ា** បាននិយាយជាចុងក្រោយថាកុំឲ្យមានការភ្ញាក់ផ្អើលចំពោះការជីករណ្តៅនេះអី ព្រោះវាជារឿងចាស់ ។

---